# ស្រីស្អាត

ពាក្យ៧

ញញឹមស្លាញស្លេញដេញពន្លឺ
ព្រោះចាំងពន្លឺពេជ្រនួនល្អង
ញញឹមស្លាញស្លេញដេញព្រាកៗ
ឲ្យរៀមសងសង្ឃឹមនិងព្រឺខ្នង
ពេជ្រអើយស្រស់សមនឹងស្រី
ឲ្យខ្ញុំនឹកពេជ្ររាល់យប់ថ្ងៃ
ជាតិនេះបើពេជ្រភ្លេចរូបបង
នឹកស្តាយត្បូងពេជ្រព្រួយឥតស្រាក់
ព្រោះបាត់ពេជ្រទៅនៅសល់អី
បានពេជ្រជួយចាំងល្អន័យជ្រៅ

ភ្នែកស្រវាំងឈឺចាប់ទាំងសង
ដែលពៅស្នេហ៍ស្នងដាំនឹងធ្មេញ។
ដើរងាកដើរងាកមករកបង
ព្រោះពេជ្រនួនល្អងចាំងខ្លាំងក្រៃ។
សមនោះសមអ្វីហួសនិស្ស័យ
នឹកហើយស្រម៉ៃលោមថ្នាក់ថ្នាក់។
ចម្បៀងសៅហ្មងតឹងអួលអាក់
ចង់ឲ្យពេជ្រចាក់ជាប់ធ្មេញពៅ។
បើភក្ត្រស្រស់ស្រីស្រស់ពេកទៅ
បើបាត់ពេជ្រទៅបានអីស្អាត។

ភ្នំពេញ ២២ធ្នូ ២០០៧
សូយ ឡុត